GC LiFE

# “គម្រោងការពារខ្លួន
# ជាក្រុម”



## តើអ្វីទៅជា “គម្រោងការពារខ្លួន” ជាក្រុម ?

“គម្រោងការពារខ្លួន” ជាក្រុម គឺជាគម្រោងធានារ៉ាប់រងដែលត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់ សហគ្រាស ស្ថាប័ន អង្គការ និងក្រុមគ្រួសាររបស់អ្នក។ គម្រោងនេះផ្តល់នូវការការពារ 24/7 សម្រាប់បុគ្គលិក និងសមាជិកគ្រួសាររបស់អ្នកមិនថាពួកគេនៅកន្លែងណាក៏ដោយ។

## តើអ្នកណាសាកសមនឹង “គម្រោងការពារខ្លួន” ជាក្រុម ?

សហគ្រាស ស្ថាប័ន អង្គការ និងក្រុមគ្រួសារណាដែលចង់ផ្តល់ការការពារដល់បុគ្គលិក ឬសមាជិកគ្រួសាររបស់ពួកគាត់។



## ហេតុអ្វីបានជាចាំបាច់ជ្រើសរើស “គម្រោងការពារខ្លួន” ជាក្រុម?

“គម្រោងការពារខ្លួន” ជាក្រុម គឺជាគម្រោងធានារ៉ាប់រងដែលមានភាពបត់បែន មានន័យថាលោកអ្នកអាចជ្រើសរើសការការពារដ៏ល្អបំផុតទៅតាមតម្រូវការរបស់លោកអ្នក។ សម្រាប់គម្រោងនេះ ក្រៅពីការការពារលើមរណភាព និងពិការភាពជាអចិន្ត្រៃយ៍ បុគ្គលិក និងសមាជិកគ្រួសាររបស់លោកអ្នកអាចបន្ថែមការការពារសម្រាប់ការចំណាយលើការពិគ្រោះជំងឺក្រៅ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងអត្ថប្រយោជន៍ផ្សេងទៀត រួមមានប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ និងប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយជំងឺគ្រុនឈាម។ល។



## លក្ខណៈនៃផលិតផល

| | |
|---|---|
| ចំនួនអ្នកត្រូវបានធានារ៉ាប់រង | 3នាក់ឡើង |
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 18 – 65ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1ឆ្នាំ |
| វិធីសាស្រ្តបង់បុព្វលាភ | បង់ម្តងផ្តាច់ |

> “ បុព្វលាភទាប ទឹកប្រាក់សំណងខ្ពស់
> ការពារបុគ្គលិក និងសមាជិកគ្រួសារ
> របស់អ្នកយ៉ាងកក់ក្តៅពេញ ៣៦៥ថ្ងៃ ”



# អត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រង

| អត្ថប្រយោជន៍ធានារ៉ាប់រង | គម្រោង Platinum<br>ទឹកប្រាក់សំណង | គម្រោង Gold<br>ទឹកប្រាក់សំណង | គម្រោង Silver<br>ទឹកប្រាក់សំណង |
|---|---|---|---|
| ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុក្នុងរយៈពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃកើតហេតុនោះ នឹងទទួលបាន៖ | $20,000 | $10,000 | $5,000 |
| ក្រោយរយៈពេលរង់ចាំ ៩០ថ្ងៃត្រូវបានបញ្ចប់ ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយសារជំងឺ នឹងទទួលបាន៖ | $4,000 | $2,000 | $1,000 |
| បុព្វលាភធានារ៉ាប់រង | $68 | $35 | $18 |

## តើលោកអ្នកត្រូវការបន្ថែមការការពារមែនទេ?

### សូមពិចារណាបន្ថែមនូវធានារ៉ាប់រងខាងក្រោម៖

● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុ
● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ប្រាក់ឧបត្ថម្ភសម្រាកនៅមន្ទីរពេទ្យដោយជំងឺគ្រុនឈាម
● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេតុ - ការពិគ្រោះជំងឺក្រៅ
● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេតុ - ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ
● ធានារ៉ាប់រងបន្ថែមជាក្រុមសម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេត - ការផ្ទេរទៅព្យាបាលនៅមន្ទីរពេទ្យក្រៅប្រទេសដោយសារស្ថានភាពធ្ងន់ធ្ងរ

## ករណីមិនធានា

១. ក្រុមហ៊ុនធានារ៉ាប់រងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ ដោយសារតែព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) អ្នកស្នើសុំធានារ៉ាប់រង ឬអ្នកទទួលផលមានចេតនាធ្វើឃាត ឬបង្ករបួសទៅលើអ្នកត្រូវបានធានារ៉ាប់រង

(២) អ្នកត្រូវបានធានារ៉ាប់រងបានប្រព្រឹត្តបទល្មើស ឬប្រឆាំងនឹងវិធានការបង្ខិតបង្ខំណាមួយតាមផ្លូវច្បាប់

(៣) អ្នកត្រូវបានធានារ៉ាប់រងធ្វើអត្តឃាត ឬបង្ករបួសលើខ្លួនឯងដោយចេតនា លើកលែងតែនៅពេលធ្វើអត្តឃាត ឬបង្ករបួសលើខ្លួនឯងនោះ អ្នកត្រូវបានធានារ៉ាប់រងបានបាត់បង់សមត្ថភាពផ្លូវច្បាប់របស់ខ្លួនដែលកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

(៤) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការវាយតប់គ្នា ឬការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន

(៥) អ្នកត្រូវបានធានារ៉ាប់រងបើកបរក្នុងស្ថានភាពស្រវឹង បើកបរក្នុងស្ថានភាពគ្រោះថ្នាក់ បើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវដែលបានកំណត់ដោយច្បាប់

(៦) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្ដែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត

(៧) អ្នកត្រូវបានធានារ៉ាប់រងខកខានមិនបានអនុវត្តតាមវេជ្ជបញ្ជាវេជ្ជសាស្ត្រ ហើយប្រើប្រាស់ ឬលេបថ្នាំដោយខ្លួនឯង (លើកលែងតែការប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា ដោយយោងតាមការណែនាំសម្រាប់ការប្រើប្រាស់)

(៨) អ្នកត្រូវបានធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រ ដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ

(៩) អ្នកត្រូវបានធានារ៉ាប់រងមានជំងឺសតិអារម្មណ៍ ឬអាកប្បកិរិយាមិនប្រក្រតី

(១០) សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរ ឬការបះបោរប្រដាប់អាវុធ

(១១) ការផ្ទុះនុយក្លេអ៊ែរ វិទ្យុសកម្មនុយក្លេអ៊ែរ ឬការចម្លងរោគពីនុយក្លេអ៊ែរ។

**បង្ហាញនូវចក្តីស្រលាញ់របស់អ្នកទៅកាន់**
**បុគ្គលិក និងសមាជិកគ្រួសាររបស់អ្នកតាមរយៈ**
**ការផ្តល់នូវការធានារ៉ាប់រងដ៏ល្អបំផុតសម្រាប់ពួកគាត់!**

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

អគារ C ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ